**ចលនានិស្សិត**
ដើម្បីលទ្ធិប្រជាធិបតេយ្យ

**បេសកកម្ម ២០២១**
ឯករាជ្យជាតិ និង សន្តិភាពថ្លៃថ្នូរ
ទឹកដីព្រំដែន និង អន្តោប្រវេសន៍
សិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ
យុត្តិធម៌សង្គម និង នីតិរដ្ឋស្អាតស្អំ

**ក្រុមប្រឹក្សាភិបាល**
លោក ម៉ែន ណាត ប្រធាន
លោក គឹម សុខ អនុប្រធាន

**គណៈកម្មាធិការប្រតិបត្តិ**
លោក ទូច វិបុល ប្រធាន
លោក អ៊ាប សេង អនុប្រធាន

**STUDENT MOVEMENT FOR DEMOCRACY (SMD)**

**Mission 2021**
National Independence and Peace
Sovereignty and Immigration
Human Rights and Democracy
Social Justice and Rule of law

**Leadership**
Men Nath, Chairman of BoD
Kim Sok, Vice Chairman of BoD
Vibol Touch, President
Eab Seng, Vice President

2402 24th St SE
Washington, DC 20020
t: 743-999-2110
e: smd2khmer@gmail.com
@: cambodiademocracy.org

*លេខ៖ ០០១/២០២១ ច.ន.ប្រ.* រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី០១ ខែមករា ឆ្នាំ២០២១

# សេចក្ដីថ្លែងការណ៍

## ភាគីជម្លោះនយោបាយខ្មែរ គួរដាក់ចេញ«សៀវភៅស» អំពីគោលការណ៍ផ្សះផ្សាផ្ទៃក្នុងជាតិ

ពលរដ្ឋខ្មែរម្ចាស់ប្រទេស ធ្លាប់បានផ្ដល់សេចក្ដីទុកចិត្តគាំទ្រ**គណបក្សប្រជាជនកម្ពុជា** និង **គណបក្សសង្គ្រោះជាតិ** ឲ្យគណបក្សទាំងពីរ មានឥទ្ធិពលកម្លាំងនយោបាយប្រហាក់ប្រហែលគ្នា ក្នុងរដ្ឋសភា កាលពីការបោះឆ្នោតជាតិឆ្នាំ២០១៣ ដើម្បីបម្រើប្រទេសជាតិ ។ **គណបក្សសង្គ្រោះជាតិ** ត្រូវបានរំលាយយ៉ាងអយុត្តិធម៌ ដោយអំណាចនយោបាយ សម្លាប់ធម្មនុញ្ញប្រជាធិបតេយ្យ ក្រោមស្លាប័នសមត្ថកិច្ចអាជ្ញា នៃ**គណបក្សប្រជាជនកម្ពុជា** កាលពីចុងឆ្នាំ២០១៧ ។ វិបត្តិជាតិ និងទុក្ខវេទនានៃប្រជាពលរដ្ឋខ្មែរ ធ្លាក់ដុនដាបហួសប្រមាណ បន្តដល់កាលៈទេសៈបច្ចុប្បន្ន ។

នៅក្នុងស្ថានការណ៍វិបត្តិដ៏ធ្ងន់ធ្ងរនេះ បើទោះបីជាក្រុមមេដឹកនាំគណបក្សធំៗ បាននាំគ្នាលើកឡើង អំពីនយោបាយផ្សះផ្សាជាតិដូចៗគ្នាក៏ដោយ ក៏ការវិវត្តជាក់ស្ដែងវិញ ឃើញម្ដងម្កាល ត្រឹមតែជាសារអក្សរខ្លីៗ ឬជាសារសម្លេងមិនប្រាកដប្រជាប៉ុណ្ណោះ ។ ក្រុមមេដឹកនាំមួយភាគធំនៃគណបក្សជម្លោះ ដើរដល់ដំណាក់កាលឈ្លោះគ្នា ដណ្ដើមអំនួតឈ្នះជាក្រុមបុគ្គល ស្ទើរតែលែងខ្វល់អំពីបំណងប្រាថ្នាដ៏ទទូចរបស់ប្រជាពលរដ្ឋ ដែលចង់បានការផ្សះផ្សាជាតិឡើងវិញ ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** យល់ឃើញថា **២០២១** គួរតែជាឆ្នាំថ្មី សម្រាប់ក្រុមអ្នកនយោបាយទាំងឡាយ ដូចជាភាគីលោក **ហ៊ុន សែន**, ភាគីលោក **សម រង្ស៊ី** និងភាគីលោក **កឹម សុខា** ដែលតែងតែតាំងខ្លួនជាអ្នកបម្រើប្រជាពលរដ្ឋនោះ ល្មមដល់ពេលវេលាបង្ហាញគោលការណ៍ជាក់លាក់ អំពីបទដ្ឋានផ្សះផ្សាជាតិ តាមរយៈ«**សៀវភៅស**»រៀងៗក្រុម ដែលអាចហៅថា«**គោលជំហរផ្សះផ្សាផ្ទៃក្នុងជាតិ**»របស់ភាគីនីមួយៗ ដើម្បីជាបង្អែកដោះស្រាយបញ្ហាប្រឈមមុខរបស់ប្រជាជាតិខ្មែរ ។

«**សៀវភៅស**»របស់ភាគីទាំងបី គួរតែចែងបញ្ជាក់អំពីចំណុចរឿង និងមូលហេតុដែលភាគីខ្លួនទាមទារ ព្រមទាំងចំណុចរឿង និងហេតុផល ដែលភាគីខ្លួនអាចអនុគ្រោះបាន ចំពោះគូប្រជែង ដើម្បីពន្លត់ជម្លោះខ្មែរ និងបញ្ចប់ការចងគំនុំសងសឹកគ្នា ។ ក្រមសីលធម៌នយោបាយ ទាំងសារថ្លែងសម្ដី និងគោលប្រតិបត្តិ ក៏គួរចែងឲ្យច្បាស់នៅក្នុង«**សៀវភៅស**» ។ យើងខ្ញុំក៏សូមលើកទឹកចិត្តដល់គណបក្សនយោបាយឯទៀត បើទោះបីជាមានកម្លាំងនយោបាយតូចនៅឡើយ ក៏គួរចងក្រង«**សៀវភៅស**»ប្រភេទនេះ ដើម្បីបង្ហាញប្រជាពលរដ្ឋម្ចាស់ឆ្នោត ក្នុងបេសកកម្មស្វែងរកការគាំទ្រនយោបាយ ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** មានជំនឿថា គ្រប់ចំណុចលក្ខខណ្ឌចែងក្នុង«**សៀវភៅស**» ដែលគណបក្សនយោបាយខ្មែរបង្ហាញនូវគោលឆន្ទៈច្បាស់លាស់ អំពីបែបបទផ្សះផ្សាជាតិនោះ នឹងក្លាយជាសេចក្ដីសច្ចាប្រណិធានជាចំហរបស់ក្រុមអ្នកនយោបាយ ចំពោះមុខពលរដ្ឋខ្មែរទូទាំងប្រទេស និងអង្គការសង្គមនានា ទាំងជាតិនិងអន្តរជាតិ លើយន្តការដោះស្រាយបញ្ហា ពេលប្រឈមជម្លោះនយោបាយ ។ ប្រជាពលរដ្ឋខ្មែរទូទៅ និងអង្គការសង្គម នឹងក្លាយជាសាក្សីដ៏មានឥទ្ធិពល ក្នុងការរួមគ្នាដាក់សម្ពាធលើគណបក្សនយោបាយណា ដែលដើរខុសគោលការណ៍ផ្សះផ្សាផ្ទៃក្នុងជាតិ តាមខ្លឹមសារឯកសារ«**សៀវភៅស**» ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** មានសេចក្ដីសង្ឃឹមថា ភាគីទាំងអស់នឹងពិចារណាប្រតិបត្តិតាមផែនទីបង្ហាញផ្លូវនេះ ដើម្បីឆ្ពោះទៅកាន់ដំណោះស្រាយវិបត្តិជាតិខ្មែរ ប្រកបដោយការជឿទុកចិត្តគ្នា ក្នុងរង្វង់ផ្ទៃក្នុងជាតិ ។ ការរួមគ្នាប្រតិបត្តិតាមគន្លងផ្លូវនេះ គឺជាពរជ័យប្រវត្តិសាស្ត្រ ក្នុងឆ្នាំថ្មី ឆ្នាំសកល២០២១ សម្រាប់បម្រើប្រជាពលរដ្ឋខ្មែរទូទៅ ។

**ប្រធានប្រតិបត្តិ**

**ទូច វិបុល**